

នាព្រឹកមួយ គីជូហានភ្ញាក់ពីព្រលឹម ហើយនិយាយទាំងស្ងាបថា

"ដល់ពេលទៅស្ទូចត្រីហើយ"។



គីជូហានជួបឆ្លូរ៉ូតាមផ្លូវទៅកាន់ស្រះទឹក។

ពួកគេទាំងពីរជាមិត្តល្អដែលតែងតែលេងជាមួយគ្នារាល់ថ្ងៃ។



មូនីយ៉ាបានឃើញពួកគេដើរដោយកាន់សន្ទូចក្នុងដៃ។

ពួកគេនិយាយទៅកាន់មូរីយ៉ាថា

"ពួកយើងកំពុងដើរទៅស្រះដើម្បីស្ទូចត្រី។

ឯងចង់ទៅជាមួយពួកយើងទេ?"



នាងតូច មូនីយ៉ាក៏បានគិតមួយសន្ទុះ ហើយឆ្លើយថា "កុំធ្វើអីចឹងអី! ត្រីនឹងងាប់ ប្រសិនបើគ្មានទឹក"។



គីជូនិងឆ្វរ៉ មិនបានស្ដាប់អ្វីដែល នាងតូចមូនីយ៉ាបាននិយាយនោះទេ។

ពួកគេក៏ដើរតម្រង់ទៅស្រះទឹកតែម្ដង។



គីជូ និងឆ្ងូរ៉ កំពុងអង្គុយស្ទូចត្រីនៅមាត់ស្រះ។ ភ្លាមនោះ ស្រាប់តែមានត្រី២ក្បាលហែលកាត់ផ្លែសន្ទូចរបស់ពួកគេ ។ ត្រីមួយក្បាលតូច និង មួយក្បាលទៀតធំ។



មួយសន្ទុះក្រោយមក ក៏មានត្រីមួយក្បាលទៀតហែលចូលមក។
វាគឺជាត្រីដ៏ធំមួយ ដែលគីជូ និងឆ្លូវមិនធ្លាប់បានឃើញពីមុនមកឡើយ
ដែលធ្វើឲ្យពួកគេភ្ញាក់ផ្អើល។ មូនីយ៉ានិយាយទាំងអស់សំណើចថា៖
"វាធំជាងជើងរបស់ឪពុកយើងទៅទៀត។



គីជូ និងឆ្ល៉ូរកាន់ដងសន្ទូចរបស់ពួកគយ៉ោងណែន។ គីជូហានស្រែកថា "ត្រីរបស់ខ្ញុំ!" ចំណែកឯឆ្ល៉ូរក៏ស្រែកដែរថា "ទេ... ត្រីរបស់ខ្ញុំទេ!"



គីជូ ប្រឹងទាញដងសន្ទូចរបស់ខ្លួនយ៉ាងខ្លាំង...

ចំណែកឯឆ្លូវវិញក៏ហានខំប្រឹងទាញសន្ទូចរបស់គេខ្លាំងជាងគីជូទៅទៀត...



ផោះ! សន្ទូចរបស់ពួកគេទាំងពីរបានលាន់ឮសំឡេងបាក់សូរផូសៗ។

គឺជូបានដួលលើដីឮសូរតព្លែស។ ចំណែកឯឆ្លូវវិញ

ក៏បានធ្លាក់ចូលទៅក្នុងស្រះឮសូរតប្លែង។



មានរឿងអ្វីកើតឡើង? តើអ្នកគិតយ៉ាងម៉េចដែរ? ការពិតត្រីទាំងនោះពាំខ្សែសន្ទូចរបស់គីជូ និងឆ្វ៊ូរចងភ្ជាប់នឹងថ្ម!

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org To read more books like this and get further information, visit letsreadasia.org .
Original Story "My fish!" "No, my fish!", author: Suraj J Menon . illustrator: Soumya Menon. Published by Pratham Books, https://storyweaver.org.in/stories/49-my-fish-no-my-fish © Pratham Books. Released under CC BY 4.0.
This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.
org/licenses/by/4.0/



# ដំណើរស្ទូចត្រីរបស់សម្លាញ់បីនាក់

Suraj J Menon